00743511

E124

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 22 / 09 / 2011
ម៉ោង (Time/Heure) : 16:15
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ឆ្នាំ ២០០៧/អវតក/អជសដ
Case File/Dossier N° 002/19-09-2007/ECCC/TC

| | |
|---|---|
| **ចំពោះមុខ** | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម **Silvia CARTWRIGHT** |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម **Jean-Marc LAVERGNE** |
| | ចៅក្រម **យូរ ឧត្តរា** |
| **កាលបរិច្ឆេទ** | ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ |
| **ភាសាដើម** | ខ្មែរ/អង់គ្លេស/បារាំង |
| **ប្រភេទឯកសារ** | សាធារណៈ |

---

# ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ*នៃវិធានផ្ទៃក្នុង

---

| **<u>សហព្រះរាជអាជ្ញា</u>** | **<u>ជនជាប់ចោទ</u>** |
|---|---|
| ជា លាង | នួន ជា |
| Andrew CAYLEY | អៀង សារី |
| | អៀង ធីរិទ្ធ |

00743512

E124

ខៀវ សំផន

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**

សុន អរុណ

Michiel PESTMAN

Victor KOPPE

អាង ឧត្តម

Michael G. KARNAVAS

ផាត់ ពៅស៊ាង

Diana ELLIS

ស សូវាន

Jacques VERGÈS

00743513



## I. សេចក្តីផ្តើម

១. នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំរៀបចំសវនាការ និងសវនាការបឋម នៅថ្ងៃទី ០៥ ខែ មេសា និង នៅ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានជម្រាបជូនដំណឹងដល់ភាគីទាំងអស់អំពីលំដាប់លំដោយនៃ ការជំនុំជម្រះលើសំណុំរឿង ០០២ ដោយបញ្ជាក់ថា អង្គជំនុំជម្រះមានបំណងចាប់ ផ្តើមសវនាការលើអង្គសេចក្តីលើសំណុំរឿង ០០២ តាមលំដាប់លំដោយដូចខាងក្រោម៖

ក) រចនាសម្ព័ន្ធរបបកម្ពុជាប្រជាធិបតេយ្យ។

ខ) តួនាទីរបស់ជនជាប់ចោទម្នាក់ៗ នៅមុនពេលមានការបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ និង នៅពេលជនជាប់ចោទម្នាក់ៗបានទទួលការចាត់តាំងនូវតួនាទីទាំងនោះ។

គ) តួនាទីរបស់ជនជាប់ចោទម្នាក់ៗក្នុងជួររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ការទទួលខុសត្រូវរបស់ពួកគេតាមការចាត់តាំង ក្របខណ្ឌនៃសិទ្ធិអំណាចរបស់ពួកគេ និងខ្សែបណ្តាញទាក់ទងនៅក្នុងរយៈកាលដែលពាក់ព័ន្ធ និងយុត្តាធិការតាមពេលវេលារបស់ អ.វ.ត.ក។

ឃ) គោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យស្តីពីបញ្ហាទាំងឡាយ ដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[១]។

២. នៅក្នុងដំណាក់កាលនោះ អង្គជំនុំជម្រះសាលាដំបូងពុំបានចេញសេចក្តីសម្រេចណាមួយ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២ អនុលោមតាមវិធាន *៨៩ស្ទួនពីរ* នៃវិធានផ្ទៃក្នុងឡើយ។ យោងតាមដីកានេះ អង្គជំនុំជម្រះសាលាដំបូងសូមជូនដំណឹងដល់ភាគីទាំងអស់ និងសាធារណៈជនឱ្យបានជ្រាបថា អនុលោមតាមវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងបានសម្រេចបំបែកកិច្ចដំណើការនីតិវិធីលើសំណុំរឿង ០០២ ទៅជាផ្នែកតូចៗ ដោយដាក់បញ្ចូលការចោទប្រកាន់លើអង្គហេតុ និងបញ្ហាអង្គច្បាប់ជាក់លាក់ដែលពាក់ព័ន្ធ។ ដើម្បីជួយសម្រួលដល់ការត្រៀមរៀបចំការជំនុំជម្រះនៅដំណាក់កាលដំបូងនេះឱ្យមានប្រសិទ្ធភាព អង្គជំនុំជម្រះសាលាដំបូងនឹងផ្តល់ជូនដល់ភាគី និងជម្រាបជូន ដល់សាធារណៈជនបានជ្រាបនូវព័ត៌មានលម្អិតអំពីផ្នែកនានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅពេលឆាប់ៗខាងមុខនេះ។

---

[១] ប្រតិចារឹក ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ (កិច្ចប្រជុំរៀបចំសវនាការ) ទំព័រ ៥២។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ (សវនាការបឋម) ទំព័រ ៨។

00743514



## ២. ការពិភាក្សាសម្រេច

៣. នៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ កិច្ចប្រជុំពេញអង្គនៃ អ.វ.ត.ក បានអនុម័តវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ដែលមានខ្លឹមសារដូចតទៅ:

**វិធាន ៨៩ស្ទួនពីរ: ការបំបែកកិច្ចដំណើរការនីតិវិធី**

(អនុម័តថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១)

នៅពេលប្រយោជន៍យុត្តិធម៌តម្រូវ នៅដំណាក់កាលណាមួយ អង្គជំនុំជម្រះសាលាដំបូង អាចបង្គាប់ឲ្យបំបែកកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងជនជាប់ចោទមួយរូប ឬ ច្រើនរូប និងផ្នែកដែលពាក់ព័ន្ធនឹងបទចោទខ្លះ ឬ ទាំងអស់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ រឿងក្តីដែលត្រូវបានបំបែក ត្រូវយកមកជំនុំជម្រះ និងវិនិច្ឆ័យចេញសាលក្រមទៅតាមលំដាប់លំដោយដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាសមស្រប។ ។

៤. យោងតាមវិធាននេះ អង្គជំនុំជម្រះសាលាដំបូងអាចបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២ ពាក់ព័ន្ធនឹងបទចោទទាំងអស់ ឬ បទចោទផ្នែកណាមួយ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលអង្គជំនុំជម្រះយល់ឃើញថា ប្រយោជន៍យុត្តិធម៌តម្រូវឲ្យធ្វើដូច្នេះ។ វិធាន ៨៩ *ស្ទួន* ពីរ នៃវិធានផ្ទៃក្នុង ក៏អនុញ្ញាតឲ្យបំបែកកិច្ចដំណើរការនីតិវិធីលើជនជាប់ចោទម្នាក់ ឬ ច្រើននាក់ផងដែរ។ ដោយហេតុថា នាពេលបច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូងបានទទួលបណ្តឹងតវ៉ាពីជនជាប់ចោទចំនួន ០២ រូប ស្តីពីបញ្ហាកាយសម្បទា និងបញ្ហាស្មារតីក្នុងការចូលរួមសវនាការ ហើយដែលសេចក្តីសម្រេចទៅ លើបណ្តឹងទាំងនេះកំពុងស្ថិតនៅក្នុងការពិចារណានៅឡើយនោះ[២] ហេតុដូច្នេះហើយដីកានេះកម្រិតត្រឹមតែលើការកំណត់កម្មវត្ថុសម្រាប់ការជំនុំជម្រះលើកដំបូងតែប៉ុណ្ណោះដោយមិនទាក់ទងទៅនឹងយុត្តាធិការលើរូបបុគ្គលរបស់អង្គជំនុំជម្រះទៅលើជនជាប់ចោទណាមួយនៅក្នុងសំណុំរឿង ០០២ នេះទេ។

៥. អង្គជំនុំជម្រះសាលាដំបូង បានសម្រេចបំបែកកិច្ចដំណើរការនីតិវិធីដើម្បីជាប្រយោជន៍នៃយុត្តិធម៌។ បន្ថែមពីលើចំណុចនានាដូចបានរៀបរាប់នៅក្នុងកថាខណ្ឌទី ១ ខាងលើ ការជំនុំជម្រះដំណាក់កាល

---

[២] *សូមមើលឧទាហរណ៍* ពាក្យសុំរបស់ នួន ជា សុំជាបន្ទាន់ចាត់តាំងអ្នកជំនាញ E30 ចុះថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១១។ សំណើរបស់មេធាវីការពារក្តី ស្នើសុំចាត់តាំងអ្នកជំនាញផ្នែកវិកលចរិត ដើម្បីវាយតម្លៃសម្បទារបស់អ្នកស្រី អៀង ធីរិទ្ធ ក្នុងការចូលរួមសវនការជម្រះក្តី E52 ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១១។

ដំបូង លើសំណុំរឿង ០០២ នេះ រួមមាន៖

ក) ការចោទប្រកាន់លើអង្គហេតុ ដែលបានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជន នៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២។

ខ) ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ រួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ (លើកលែងដោយហេតុផលសាសនា) ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ ( ដោយហេតុថា អង្គហេតុទាំងនេះពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន នៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២)។

៦. នៅក្នុងដំណាក់កាលណាមួយក៏បាន អង្គជំនុំជម្រះសាលាដំបូងអាចសម្រេចដាក់បញ្ចូលបន្ថែមនូវផ្នែកផ្សេងទៀតនៃដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២ ប្រសិនបើសិទ្ធិដែលត្រូវទទួលបានការការពារខ្លួន ត្រូវបានផ្តល់ជូននូវឱកាសក្នុងការរៀបចំការការពារបានប្រកបដោយប្រសិទ្ធភាព ហើយនិងភាគីនានាត្រូវបានជូនដំណឹងក្នុងរយៈពេលសមស្រប។ នៅពេលបញ្ចប់ការជំនុំជម្រះលើកដំបូងនេះ អង្គជំនុំជម្រះនឹងចេញសាលក្រមពាក់ព័ន្ធនឹងការចោទប្រកាន់ទាំងនេះដោយផ្តន្ទាទោសសមស្រប ប្រសិនបើរកឃើញថា មានពិរុទ្ធភាព ។

៧. អង្គហេតុពាក់ព័ន្ធនឹងសហករណ៍ ការដ្ឋាន មន្ទីរសន្តិសុខ កន្លែងសម្លាប់មនុស្ស ឬ អង្គហេតុពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជននៅក្នុងដំណាក់កាលទី ៣ នឹងមិនត្រូវបានលើកយកមកដេញដោលនៅក្នុងការជំនុំជម្រះលើកដំបូងនេះទេ។ លើសពីនេះទៀត *បទចោទប្រកាន់ទាំងអស់ ដូចជា* បទប្រល័យពូជសាសន៍ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ ត្រូវ ទុកដើម្បីលើកយកទៅដេញដោលនៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីក្រោយៗទៀតនៅក្នុងសំណុំរឿង ០០២។

៨. ផ្អែកលើបទដ្ឋានគតិយុត្តជាធរមាន ដើមបណ្តឹងរដ្ឋប្បវេណី មិនចូលរួមជាលក្ខណៈបុគ្គល ដោយផ្អែកលើមូលដ្ឋាននៃព្យសនកម្មជាក់លាក់ដែលខ្លួនបានទទួលរងឡើយ ផ្ទុយទៅវិញដើមបណ្តឹងរដ្ឋ-ប្បវេណីទាំងនេះ រួមបញ្ចូលជាបណ្តុំដើមបណ្តឹងរដ្ឋប្បវេណី ដែលបានរួមគ្នាជាក្រុមតែមួយដែលផលប្រយោជន៍សមូហភាពរបស់ពួកគេ នឹងត្រូវតំណាងដោយសហមេធាវីនាំមុខតំណាងដើម

បណ្ដឹងរដ្ឋប្បវេណី នៅក្នុងអំឡុងពេលជំនុំជម្រះ និងដំណាក់កាលក្រោយៗមកទៀត[៣]។ ហេតុដូច្នេះ ការកម្រិតវិសាលភាពនៃអង្គហេតុ ដែលគ្រោងនឹងយកមកជំនុំជម្រះ នៅក្នុងដំណាក់កាលដំបូងនេះ ពុំមានផលប៉ះពាល់ចំពោះការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងពេលជំនុំជម្រះនេះឡើយ។ ចំណែកការទាមទារសំណង ដែលធ្វើឡើងដោយសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក៏គួរគិតពិចារណាលើវិធាន ២៣ *ស្ទួនបួន* (១)(ក) នៃវិធានផ្ទៃក្នុងផងដែរ[៤]។ ចំនួនសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី ដែលអង្គជំនុំជម្រះសាលាដំបូងគ្រោងនឹងកោះហៅ ក៏នឹងត្រូវកម្រិតត្រឹមតែបុគ្គលទាំងឡាយ ដែលអង្គជំនុំជម្រះយល់ឃើញថា ចាំបាច់ត្រូវយកមកដេញដោលនៅ ក្នុងការជំនុំជម្រះដំណាក់កាលដំបូងនេះតែប៉ុណ្ណោះ។ ការបំបែកកិច្ចដំណើរការនីតិវិធីនឹងផ្ដល់ លទ្ធភាពឲ្យអង្គជំនុំជម្រះអាចចេញសាលក្រមបាន បន្ទាប់ពីការជំនុំជម្រះខ្លីនេះ ការពារបាននូវផលប្រយោជន៍ជាសារវ័ន្តរបស់ជនរងគ្រោះក្នុងការទទួលបាននូវយុត្តិធម៌ប្រកបដោយអត្ថន័យនិង ទាន់ពេលវេលា ព្រមទាំងការពារបាននូវសិទ្ធិទទួលបានការជំនុំជម្រះដោយឆាប់រហ័សរបស់ជនជាប់ចោទ ទាំងអស់នៅក្នុងសំណុំរឿង ០០២ ទៀតផង។

៩. អង្គជំនុំជម្រះសាលាដំបូងបានទទួលញត្តិមួយចំនួនពីភាគី ដែលខ្លឹមសារនៃញត្តិទាំងនោះ នឹងទទួលរងនូវអានុភាពដោយដីកានេះ។ នៅថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១១ ក្រុមមេធាវីការពារក្ដី អៀង សារី បានស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង ចុះពិនិត្យទីកន្លែង "ដើម្បីអាចសង្កេតមើលភូមិសាស្ត្រ សភាពនៃទីតាំង និងទំនាក់ទំនងជារូបវ័ន្តរវាងទីតាំងនានា ដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ"[៥]។ ដោយហេតុថា នៅក្នុងដំណាក់កាលនេះ ពុំមានសហករណ៍ ការដ្ឋាន មន្ទីរសន្តិសុខ ឬ កន្លែងសម្លាប់ណាមួយ ត្រូវបានយកមកដាក់បញ្ចូលនៅក្នុងក្របខណ្ឌនៃការជំនុំជម្រះលើកដំបូងទេនោះ ហេតុដូច្នេះ សេចក្ដីសម្រេចលើសំណើនេះ គឺមិនចាំត្រូវធ្វើឡើង

---

[៣] វិធាន ២៣(៣)នៃវិធានផ្ទៃក្នុង។

[៤] វិធាន ២៣ *ស្ទួនបួន* (១)(ក) នៃវិធានផ្ទៃក្នុងចែងថា "...តាមគោលបំណងនៃវិធានទាំងនេះ សំណងផ្លូវចិត្ត និងសមូហភាព គឺជាវិធានការទាំងឡាយដែល...ទទួលស្គាល់នូវការខូចខាតដែលដើមបណ្ដឹងរដ្ឋប្បវេណីទទួលរងដោយសារការប្រព្រឹត្តនូវបទឧក្រិដ្ឋរបស់ជនជាប់ចោទដែលត្រូវបានផ្ដន្ទាទោស"។

[៥] សំណើរបស់ អៀង សារី សុំឲ្យអង្គជំនុំជម្រះសាលាដំបូងចុះពិនិត្យដល់ទីកន្លែង E113 ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១១ កថាខណ្ឌផ្ដើម។

នៅក្នុងពេលនេះឡើយ[៦]។ ក្រោយពីពិចារណាលើកម្មវត្ថុនៃការជំនុំជម្រះលើកដំបូងនេះមក សេចក្ដីសម្រេចលើ "សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យអង្គជំនុំជម្រះសាលាដំបូង កំណត់បទល្មើសសារជាថ្មីទាក់ទងនឹងអង្គហេតុនៃការរំលោភសេពសន្ថវៈ ថាជាបទរំលោភសេពសន្ថវៈនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាជាងថាជាអំពើអមនុស្សធម៌ផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" (E99) មិនទាន់ត្រូវសម្រេចនៅពេលនេះទេ ដោយគួរទុកយកទៅយកទៅសម្រេចនៅក្នុងដំណាក់ការជំនុំជម្រះក្រោយៗទៀត។ សេចក្ដីសម្រេចឆ្លើយតបទៅនឹងផ្នែកមួយចំនួននៅក្នុងញត្តិរបស់ អៀង សារី ស្នើសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយដោយសារកំហុសនីតិវិធី (E58) ក៏មានហេតុផលដូចគ្នាផងដែរ ពោលគឺនឹងទុកយកទៅសម្រេចនៅពេលក្រោយ[៧]។

**យោងលើសំអាងហេតុដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូង ÷**

**សម្រេច** បំបែកកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២ លើបទចោទ និងការចោទប្រកាន់លើអង្គហេតុ ដូចបានរៀបរាប់នៅក្នុងកថាខណ្ឌ ៥ នៃដីកានេះ ។

---

[៦] សំណើសុំលេខ E113 ពុំបានយោងជាក់លាក់លើទីតាំងបទល្មើសទាំងឡាយ ដែលពាក់ព័ន្ធនឹងការជំនុំជម្រះលើកដំបូងនេះ ទេ (សំណើរបស់ អៀង សារី សុំឲ្យអង្គជំនុំជម្រះសាលាដំបូងចុះពិនិត្យដល់ទីកន្លែង E113 ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១១ កថាខណ្ឌផ្ដើម)។

[៧] *សូមមើល ឧទាហរណ៍* ញត្តិរបស់ អៀង សារី ស្នើសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយដោយសារកំហុសនីតិវិធី E58 ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ៧-១១ (ជាប់ពាក់ព័ន្ធនឹងបទប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ សេចក្ដីសម្រេចលើអញ្ញត្រកម្មនានារបស់ភាគីពាក់ព័ន្ធទៅនឹងបញ្ហាស្រដៀងគ្នានេះ នឹងចេញនៅពេលក្រោយ។ អញ្ញត្រកម្មរបស់ អៀង ធីរិទ្ធ លើយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង E44 ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ២៥-៣០ (ជាប់ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភនៅក្នុងបទល្មើសនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ)។ សេចក្ដីសង្ខេបអញ្ញត្រកម្មរបស់ អៀង សារី តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង [...] E51/4 ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ២៧(ង) (ដាក់បញ្ចូលដោយយោងលើសារណានានាពីពេលមុន នូវលក្ខណៈវិនិច្ឆ័យនៃការកំណត់បទចោទ និងនិយមន័យនៃការធ្វើទារុណកម្ម និងការដាក់ក្នុងមន្ទីរឃុំឃាំង ជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ)។

**បញ្ជាក់ថា** អង្គជំនុំជម្រះនឹងជូនព័ត៌មានលម្អិតបន្ថែម ក្នុងពេលឆាប់នេះៗ ជូនដល់ភាគី និងសាធារណៈជនឲ្យបានជ្រាប អំពីកថាខណ្ឌ និងផ្នែកណានានាដែលមាននៅក្នុងដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងការជំនុំជម្រះលើកដំបូងលើសំណុំរឿង ០០២ នេះ។

**ពន្យារ** ការសម្រេចលើបណ្តឹងដែលមានលេខ E59, E99 និង E113 ព្រមទាំងបញ្ហាដែលនៅសេសសល់ ដូចបានលើកឡើងនៅក្នុងកថាខណ្ឌ ៩ នៃដីកានេះ ដោយទុកយក ទៅសម្រេចនៅក្នុងកិច្ចដំណើរការនីតិវិធី នៅក្នុងដំណាក់កាលក្រោយៗ។

**បញ្ជាក់ថា** ព័ត៌មានបន្ថែមពាក់ព័ន្ធការជំនុំជម្រះនៅដំណាក់បន្ទាប់លើសំណុំរឿង ០០២ នឹងផ្តល់ជូនដល់ភាគី និងសាធារណៈជន ឲ្យបានជ្រាបនាពេលសមស្របខាងមុខ។

ភ្នំពេញ ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**និល ណុន**